## ក្រសួងមហាផ្ទៃ និងUNODC ប្រារព្ធពិធីកិច្ចប្រជុំស្តីពីការរួមកម្លាំងដើម្បី ពង្រឹងវិធានការបង្ក្រាបការរត់ពន្ធជនទេសន្តរប្រវេសន៍: ទិសដៅទៅអនាគត

*Friday, 08 March 2013 00:00*



Interior Info - ភ្នំពេញថ្ងៃទី០៨ ខែមិនា ឆ្នាំ ២០១៣




ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់

នៅវេលាម៉ោង ២ រសៀលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ២០១៣ នៅសណ្ឋាគារ LE ROYAL មានប្រារព្ធពិធីកិច្ចប្រជុំពីការរួមកម្លាំងដើម្បី ពង្រឹងវិធានការបង្ក្រាបការរត់ពន្ធជនទេសន្តប្រវេសន៍: ទិសដៅទៅអនាគត ដែលរៀបចំដោយក្រសួងមហាផ្ទៃនិងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ កិច្ចប្រជុំនេះមានការចូលរួមពីសំណាក់ តំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា និងអង្គការជាដៃគូជាច្រើនទៀត។



ទិដ្ឋភាពរួមសមាជិកកិច្ចប្រជុំ



ទិដ្ឋភាពរួមសមាជិកកិច្ចប្រជុំ

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ ក្នុងសុន្ទរកថា បើកកិច្ចប្រជុំ ថា "ការទប់ស្កាត់ការរត់ពន្ធជនទេសន្តរប្រវេសន៍ ការជួញដូរមនុស្សក៏កាន់តែមានភាពស្មុគស្មាញ ទាមទារឱ្យមាន ការបណ្តុះបណ្តាល ដែលមានយុទ្ធសាស្ត្រច្បាស់លាស់ ព្រមទាំងការបំពាក់សំភារៈទំនើបផងដែរ"។



ឯកឧត្តម សៀង ឡាប្រេស្ស ថ្លែងសុន្ទរកថាស្វាគមន៍



លោក Olivier Lermet ថ្លែងសុន្ទរកថាណែនាំ




លោក Sebastian Baumeister ធ្វើបទបង្ហាញស្តីពីគម្រោងCAU




លោក Giovanni Broussard ធ្វើបទបង្ហាញស្តីពីគម្រោងPATROL




តំណាងស្ថានទូតអូស្ត្រាលី កិច្ចសហប្រតិបត្តិការ អូស្ត្រាលី និងកម្ពុជា




លោក Martin Reeve ធ្វើបទបង្ហាញស្តីពីគម្រោងPIU



តំណាងស្ថានទូតកាណាដា កិច្ចសហប្រតិបត្តិការ កាណាដា និងកម្ពុជា

ឯកឧត្តម ស ខេង ក៏បានប្រកាសក្នុងកិច្ចប្រជុំអំពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវៈ នីតិវិធីប្រតិបត្តិការស្តង់ដារ PIU, សៀវភៅទៅបណ្តុះបណ្តាលជាមូលដ្ឋានស្តីអំពីការស៊ើបអង្កេតនិងការផ្តន្ទាទោសអំពើរត់ពន្ធជនទេសន្តរប្រវេសន៍និង ខិតប័ណ្ណស្តីពីអំពើជួញដូរមនុស្សអំពីរត់ពន្ធទេសន្តរប្រវេសន៍ ចាប់ពីពេលនេះតទៅ។




ឯកឧត្តម ស ខេង ថ្លែងសុន្ទរកថា បើកកិច្ចប្រជុំ




គួររំលឹកផងដែរ អស់រយៈពេល ពីរឆ្នាំ ដប់ខែ ម្ភៃប្រាំបួនថ្ងៃ កន្លងទៅ បន្ទាប់ពីលិខិតនៃកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខានៅ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១០ រវាងក្រសួងមហាផ្ទៃ និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុក ការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្ម ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍, ក្រុមការងាររបស់ក្រសួងមហាផ្ទៃ និង UNODC បានចូលរួមប្រជុំពិគ្រោះយោបល់ តាក់តែងផែនការសកម្មភាពដើម្បីអនុវត្តន៍លិខិតនៃកិច្ចព្រមពៀងដែលមានគំរោងលេខ XSPT78 ឆ្ពោះទៅបំប៉នចំណេះដឹងផ្តល់គ្រឿងឧបករណ៍ និងបង្កើត៖ អង្គភាពសម្របសម្រួល និងវិភាគសកម្មភាពរត់ពន្ធជនទេសន្តរប្រវេសន៍ (CAU), អង្គភាពចារកម្មកំពង់ផែ ចែករំលែកព័ត៌មានព្រហ្មទ័ណ្ឌឲ្យចំគោលដៅ បង្ក្រាបការរត់ពន្ធទេសន្តរប្រវេសន៍តាមផ្លូវទឹក (PIU) និងអង្គភាពទំនាក់ទំនងព្រំដែនគោកទប់ស្កាត់ការរត់ពន្ធជនទេសន្តរប្រវេសន៍ (PATROL)។

កិច្ចប្រឹងប្រែងរួមរបស់មន្ត្រីក្រសួងមហាផ្ទៃនិង UNODC ក្នុងរយៈពេល ពីរឆ្នាំ ដប់ខែ ម្ភៃប្រាំបួនថ្ងៃនេះ បានទទួលសមិទ្ធិផលគួរជាទីមោទនៈ ។

នាឱកាសបើកកិច្ចប្រជុំនេះក៏មានពិធីចុះហត្ថលេខាលើលិខិតព្រមព្រៀងស្តីពីគម្រោង PIU និងប្រគល់សំភារៈបរិក្ខាគម្រោង PIU ផងដែរ៕




ពិធីចុះហត្ថលេខាលើលិខិតព្រមព្រៀងស្តីពីគម្រោងPIU




07/03/2013

